# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 799

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងសាងសង់មជ្ឈមណ្ឌលភស្តុភារកម្មភ្នំពេញ

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/25

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/27

៣. ចំណាយគម្រោងសរុប $125,000,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងសាធារណការ និងដឹកជញ្ជូន

RESPONSIBLE UNIT General Department of Logistics

អង្គភាពទទួលខុសត្រូវ នាយកដ្ឋានសហប្រតិបត្តិការភស្តុភារកម្ម នៃអគ្គនាយកដ្ឋានភស្តុភារកម្ម

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

អភិវឌ្ឍន៏ធនធានមនុស្ស បណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធនឹងគម្រោង ជំរុញការចូលរួមពីវិស័យឯកជនក្នុងការអភិវឌ្ឍន៍វិស័យឡជិស្ទីកតាមរយៈការពង្រឹងយន្តការ "ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន"។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ការដឹកជញ្ជូន

Railways

Logistics

Ports and Waterways

Logistics

១២. ទីតាំងអនុវត្តគម្រោង ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

គោលបំណងនៃគម្រោងគឺបន្តអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ រួមជាមួយនឹង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ឱ្យក្លាយទៅជាប្រព័ន្ធឡជិស្ទីកមួយដ៏រស់រវើក មានសុវត្ថិភាព តម្លាភាព ក្នុងគោលដៅកាត់បន្ថយតម្លៃសេវាដឹកជញ្ជូនឱ្យមានកម្រិតប្រកួតប្រជែងធៀបទៅនឹងប្រទេសជិតខាង និងមានប្រសិទ្ធភាពសំដៅរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ និងសុខុមាលភាពរបស់ប្រជាជន។

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

o ២០១៩ - ២០២០   សិក្សាគម្រោងជាក់ស្តែង ( Feasible Study )

o ២០២១ - ២០២៣   ទិញដីសាងសង់ចំណតរថយន្តធនធ្ងន់សាធារណៈ ( Public Truck Terminal )

សាងសង់ឃ្លាំងត្រជាក់ ( Cold Storage )

សាងសង់ហេដ្ឋារចនាសម្ព័នមូលដ្ឋាន ( Basic Infrastructure )

o ២០២៤ - ២០២៦   សាងសង់មជ្ឈមណ្ឌលបែងចែកសម្រាប់ក្រុមហ៊ុនឯកជន ( Distribution Center for private companies )

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

យោងលើហេតុផលកើនឡើងជាលំដាប់នៃទំនិញនាំចេញនាំចូលពីមួយឆ្នាំទៅមួយឆ្នាំឥតឈប់ឈរ ស្របទៅនឹងកំណើនសេដ្ឋកិច្ចជាតិ និងចំណូលរបស់ប្រជាពលរដ្ឋ នាំមកនូវការកើនឡើងនៃវិស័យដឹកជញ្ជូន និងឡជិស្ទីក។ យ៉ាងណាមិញ ទំនិញចេញពីរោងចក្រសហគ្រាស សម្ភារៈសាងសង់ និងទំនិញប្រើប្រាស់ប្រចាំថ្ងៃ មានចរាចរណ៍មមាញឹកខ្លាំងនៅទីក្រុងភ្នំពេញ។ រោងចក្រសហគ្រាស និងតំបន់សេដ្ឋកិច្ចពិសេសជាច្រើន ក៏ដូចជាក្រុមហ៊ុនបំរើសេវាកម្មឡជិស្ទីក មាន ផែស្ទួតជាដើមដែលទាក់ទាញការដឹកជញ្ជូនទំនិញធំៗ មានរាយប៉ាយតាមជាយក្រុងភ្នំពេញ។ ទាំងនេះ នាំមកនូវសេវាកម្មឡជិស្ទីកគ្មានប្រសិទ្ធភាព ហើយក៏ជាដើមហេតុនៃការកកស្ទះចរាចរនៅរាជធានីភ្នំពេញផងដែរ។ ផ្ទុយទៅវិញ នៅតាមតំបន់ជាយរាជធានីបច្ចុប្បន្នកំពុងមានការកើនឡើងឥតឈប់ឈរនូវបរិមាណរថយន្តធំៗ ជាលទ្ធផលនាំឱ្យមានការរិតបន្តឹងនៃចរាចររថយន្តធនធ្ងន់ចូលក្នុងរាជធានីនៅពេលថ្ងៃ។ បន្ថែមពីនេះ ការដឹកជញ្ជូនទំនិញ កំពុងមានតម្រូវការខ្លាំងនៅទីប្រជុំជនក្នុងការបញ្ជូនទំនិញឱ្យមានប្រសិទ្ធភាព។ បើយោងតាមការសិក្សាស្រាវជ្រាវរបស់អង្គភាព KOICA កាលពីឆ្នាំ ២០១៤ បង្ហាញឱ្យឃើញថា មានតម្រូវការបង្កើតឱ្យមាន Logistics Complex មួយនៅក្នុងរាជធានីភ្នំពេញ និងនៅតាមតំបន់មានទីក្រុង។ ហេតុដូច្នេះហើយ ការបង្កើតឱ្យមាន Logistics Complex នៅក្នុងរាជធានីភ្នំពេញ នាំមកនូវការបង្កើនប្រសិទ្ធភាពសេវាកម្មដឹកជញ្ជូន ក៏ដូចជាជួយកាត់បន្ថយការកកស្ទះចរាចរនៅក្នុងរាជធានី។ ម្យ៉ាងវិញទៀតគឺជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងស្រុក ក៏ដូចជាជាមួយអន្តរជាតិផងដែរ។

១៦. ផលប្រយោជន៍របស់គម្រោង ( រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង )

o ទទួលបានសេវាកម្មដឹកជញ្ជូន និងបញ្ជូនទំនិញយ៉ាងមានប្រសិទ្ធភាព

o ធ្វើសេវាកម្មឡជិស្ទីកនៅក្នុងកុំផ្លិកទំនើបបានយ៉ាងឆាប់រហ័ស

o បង្កើនប្រសិទ្ធភាពត្រួតពិនិត្យចរាចរទំនិញចេញចូលក្នុងក្រុងបានច្រើនដោយសាមានសេវាឡជិស្ទីកនៅជាយរាជធានី

o មានប្រសិទ្ធភាពក្នុងការប្រើប្រាស់ដីធ្លីនៅតាមតំបន់ជាយរាជធានី

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះពុំមានផលប៉ះពាល់ដល់ប្រជាជននិងបរិស្ថានទេ**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះមិនមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីទេផ្ទុយទៅវិញគម្រោងនេះនឹងផ្តល់ផលប្រយោជន៍សំរាប់យុវជន**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**អគ្គនាយកដ្ឋានកស្តុភារកម្មមិនមានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងនេះទេ ប៉ុន្តែដោយសាគម្រោងនេះជាប្រភេទគម្រោង "ភាពជាដៃគូរវាងរដ្ឋនិងឯកជន" ចាំបាច់ត្រូវសហការជាមួយអ្នកជំនាញពីវិស័យឯកជន ទាំងការសិក្សាគម្រោងជាក់ស្តែង ទាំងការសាងសង់ និងទាំងការបណ្តុះបណ្តាលការ [illegible]**

២៣. [illegible] គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាល ឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

o សំណើគម្រោងស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និងបានសម្រេចទទួលយកសំណើរួចមកហើយពីក្រសួងសេដកិច្ច និងហិរញ្ញវត្ថុ
o ការពិភាក្សាលើសំណើគម្រោងបានប្រព្រឹត្តទៅច្រើនដងរួចមកហើយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែលទ្ធផលបានត្រឹមតែទុកចាំពិចារណាបន្ត។

បញ្ហាប្រឈមរបស់គម្រោងគឺ៖

o មិនទាន់ចេញសេចក្តីសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុញ្ញាតិឱ្យគម្រោងបានចាប់ផ្តើមធ្វើការសិក្សាលម្អិតរបស់គម្រោង
o មិនទាន់សម្រេចលើថវិកាសម្រាប់ដំណើរការគម្រោង។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

2

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

o ធនាគារពិភពលោក
o ធនាគារអភិវឌ្ឍអាស៊ី ADB
o JICA

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 3,085.7 | 4,037.3 | 4,457.4 | 11,580.4 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 1,000.0 | 2,000.0 | 2,000.0 | 5,000.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 1,783.6 | 2,032.4 | 1,507.7 | 5,323.7 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 302.1 | 4.9 | 949.7 | 1,256.7 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 3,085.7 | 4,037.3 | 4,457.4 | 11,580.4 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 3,085.7 | 4,037.3 | 4,457.4 | 11,580.4 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: